ក្រសួងអប់រំរដ្ឋ NSW

Behaviour code for students

Information for students and parents or carers

# ច្បាប់ឥរិយាបថសម្រាប់សិស្ស

## ព័ត៌មានសម្រាប់សិស្ស និងឪពុកម្ដាយ ឬអ្នកថែទាំ

សាលារៀនរដ្ឋក្នុងរដ្ឋ NSW ប្ដេជ្ញាផ្ដល់នូវបរិយាកាសរៀនសូត្រប្រកបដោយសុវត្ថិភាព ការគាំទ្រ និងការឆ្លើយតប សម្រាប់មនុស្សគ្រប់រូបនៅទូទាំងកន្លែងជាច្រើន។ យើងបង្រៀន និងធ្វើគំរូឥរិយាបថដែលរាប់បញ្ចូល និងមានសុវត្ថិភាព ដែលយើងឱ្យគុណតម្លៃចំពោះសិស្សរបស់យើង។

### នៅសាលារៀនក្នុងរដ្ឋ NSW សិស្សត្រូវបានរំពឹងថានឹងខិតខំអស់ពីសមត្ថភាពរបស់ពួកគេដើម្បី៖

- បង្ហាញការគោរពចំពោះសិស្សដទៃទៀត គ្រូបង្រៀនរបស់ពួកគេ និងបុគ្គលិកសាលា ហើយនិងសមាជិកសហគមន៍
- អនុវត្តតាមវិន័យសាលា និងថ្នាក់រៀន ហើយធ្វើតាមការណែនាំរបស់គ្រូពួកគេ
- ប្រឹងប្រែងសម្រេចឱ្យបាននូវស្តង់ដារខ្ពស់បំផុតក្នុងការរៀនសូត្រ
- ប្រព្រឹត្តប្រកបដោយការគួរសម និងគួរឱ្យគោរព ដែលធ្វើឱ្យសមាជិកទាំងអស់នៃសហគមន៍សាលា មានអារម្មណ៍ថាមានគុណតម្លៃ ត្រូវបានរួមបញ្ចូល និងគាំទ្រ
- ដោះស្រាយជម្លោះប្រកបដោយការគោរព ស្ងប់ស្ងាត់ និងយុត្តិធម៌
- បំពេញតាមគោលនយោបាយឯកសណ្ឋាន ឬច្បាប់ស្ដីពីការស្លៀកពាក់ដែលបានព្រមព្រៀងគ្នារបស់សាលារៀន
- មករៀនរៀងរាល់ថ្ងៃ (លុះត្រាតែត្រូវបានលើកលែងស្របច្បាប់)
- គោរពថែរក្សាទ្រព្យសម្បត្តិទាំងអស់
- មានសុវត្ថិភាព និងមិនត្រូវប្រើហិង្សា ឬនាំយកអាវុធ គ្រឿងញៀនខុសច្បាប់ គ្រឿងស្រវឹង ឧបករណ៍ស្រូបចំហាយបារីអេឡិចត្រូនិច (vapes), បារីអេឡិចត្រូនិច ឬថ្នាំជក់ចូលមកក្នុងសាលារៀនរបស់យើង
- មិនត្រូវសម្លុតធ្វើបាប បៀតបៀន បំភិតបំភ័យ ឬប្រកាន់រើសអើងនរណាម្នាក់នៅក្នុងសាលារៀនរបស់យើង។

សាលារៀនចាត់វិធានការក្នុងការឆ្លើយតបទៅនឹង ឥរិយាបថដែលបង្កគ្រោះថ្នាក់ដល់ខ្លួនឯង ឬអ្នកដទៃទៀត ឬដល់សមិទ្ធផលនៃការបង្រៀន និងការរៀនសូត្រប្រកបដោយគុណភាពខ្ពស់។

### សិស្សទាំងអស់មានសិទ្ធិ៖

- មានសុវត្ថិភាពនៅសាលារៀន
- ចូលប្រើប្រាស់ និងចូលរួមយ៉ាងពេញលេញក្នុងការរៀនសូត្ររបស់ពួកគេ
- ត្រូវបានប្រព្រឹត្តដោយការគោរពពីសិស្សដទៃទៀត គ្រូបង្រៀន និងបុគ្គលិកសាលា
- បង្ហាញពីទស្សនៈរបស់ពួកគេ កំណត់គោលដៅ និងការតស៊ូមតិដោយខ្លួនឯង។

នាយកសាលា និងបុគ្គលិកសាលា ដោយប្រើការវិនិច្ឆ័យប្រកបដោយជំនាញវិជ្ជាជីវៈរបស់ពួកគេ មានសមត្ថភាពខ្ពស់បំផុតដើម្បីរក្សាវិន័យ និងផ្ដល់នូវបរិយាកាសរៀនសូត្រប្រកបដោយសុវត្ថិភាព ការគាំទ្រ និងឆ្លើយតប ហើយអនុវត្តសកម្មភាពសមស្របមួយ នៅពេលណាសិស្សមិនបំពេញតាមការរំពឹងទុកទាំងនេះ។

ក្រសួងទទួលខុសត្រូវចំពោះការផ្ដល់ក្របខ័ណ្ឌគោលនយោបាយ និងធនធាននានា ដូចជាព្រឹត្តិបត្រអំពីបញ្ហាច្បាប់ ការទទួលបានដំបូន្មានពីអ្នកឯកទេស និងការរៀនជំនាញវិជ្ជាជីវៈ ដើម្បីណែនាំនាយកសាលា និងបុគ្គលិករបស់ខ្លួន ក្នុងការអនុវត្តការវិនិច្ឆ័យប្រកបដោយជំនាញវិជ្ជាជីវៈរបស់ពួកគេ។

នៅក្នុងបរិបទនេះ រដ្ឋាភិបាលរដ្ឋ NSW និងក្រសួងអប់រំ នឹងគាំទ្រសិទ្ធិអំណាច និងការវិនិច្ឆ័យរបស់នាយកសាលា និងបុគ្គលិកសាលានៅកម្រិតមូលដ្ឋាន។

### ច្បាប់ឥរិយាបថសម្រាប់សិស្ស៖ សកម្មភាពសិស្ស

ការលើកកម្ពស់ការរាប់បញ្ចូល ការរៀនសូត្រ សុខុមាលភាព និងសុវត្ថិភាពរបស់សិស្សទាំងអស់នៅសាលារៀនក្នុងរដ្ឋ NSW គឺជាអាទិភាពខ្ពស់សម្រាប់ក្រសួងអប់រំ។

យើងអនុវត្តវិធីសាស្ត្របង្រៀន និងរៀនសូត្រនៅទូទាំងកន្លែងជាច្រើន ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍ជំនាញដែលសិស្សត្រូវការ ដើម្បីបំពេញតាមស្តង់ដារខ្ពស់របស់យើង សម្រាប់ឥរិយាបថប្រកបដោយការគោរព សុវត្ថិភាព និងការចូលរួម។

**ដើម្បីបំពេញតាមការរំពឹងទុកដែលបានកំណត់ខាងលើ សិស្សនៅសាលារៀនក្នុងរដ្ឋ NSW គួរតែប្រកាន់ខ្ជាប់នូវគោលការណ៍នានាដូចខាងក្រោម ឱ្យអស់ពីសមត្ថភាពរបស់ពួកគេ។**

## ការគោរព

- ប្រព្រឹត្តចំពោះគ្នាទៅវិញទៅមកដោយសេចក្តីថ្លៃថ្នូរ។
- ប្រាស្រ័យទាក់ទងគ្នា និងមានឥរិយាបថគួរសម។
- ធ្វើសកម្មភាព និងធ្វើកិច្ចសហប្រតិបត្តិការជាមួយសិស្សដ៏ទៃទៀត គ្រូបង្រៀន និងបុគ្គលិកសាលា។
- បង្កើតទំនាក់ទំនងវិជ្ជមាន និងដោយការគោរព។
- ឱ្យគុណតម្លៃទៅលើផលប្រយោជន៍ សមត្ថភាព និងវប្បធម៌របស់អ្នកដទៃ។
- គោរពចំពោះតម្រូវការរៀនសូត្ររបស់សិស្សដទៃ។
- ស្លៀកពាក់ឱ្យបានសមរម្យ ដោយស្លៀកពាក់ឯកសណ្ឋានសាលា ឬច្បាប់ស្តីពីការស្លៀកពាក់ ដែលបានព្រមព្រៀងគ្នា។
- ថែរក្សាទ្រព្យសម្បត្តិសាលា និងទ្រព្យសម្បត្តិរបស់បុគ្គលិក និងសិស្សដទៃទៀត។

## សុវត្ថិភាព

- ធ្វើជាគំរូ ហើយអនុវត្តតាមវិន័យសាលា និងថ្នាក់រៀន និងការរំពឹងទុកជុំវិញឥរិយាបថ និងការប្រព្រឹត្ត។
- ចរចា និងដោះស្រាយជម្លោះ។
- ត្រូវប្រយ័ត្ន និងទទួលខុសត្រូវចំពោះអាកប្បកិរិយា និងសកម្មភាពរបស់ខ្លួនដែលធ្វើឱ្យប៉ះពាល់ដល់អ្នកដទៃទៀត។
- យកចិត្តទុកដាក់ចំពោះខ្លួនឯង និងអ្នកដទៃទៀត។
- ត្រូវមានសុវត្ថិភាព និងជួយអ្នកដទៃឱ្យធ្វើការជ្រើសរើសដោយសុវត្ថិភាព មិនធ្វើឱ្យប៉ះពាល់ដល់ខ្លួនឯង ឬអ្នកដទៃ។

## ការចូលរួម

- មកដល់សាលារៀន និងថ្នាក់រៀនទាន់ពេល។
- ត្រៀមខ្លួនសម្រាប់រៀងរាល់មេរៀននីមួយៗ។
- ចូលរួមយ៉ាងសកម្មក្នុងការរៀនសូត្រ។
- ប្រាថ្នា និងខិតខំដើម្បីសម្រេចឱ្យបាននូវស្តង់ដាររៀនសូត្រខ្ពស់បំផុត។

### សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ

ប្រសិនបើអ្នកត្រូវការព័ត៌មានបន្ថែម សូមទូរសព្ទទៅនាយកសាលា។ ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ ដើម្បីជួយអ្នកក្នុងការសាកសួររបស់អ្នក សូមទូរសព្ទមក សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទលេខ 131 450 ហើយស្នើសុំអ្នកបកប្រែផ្ទាល់មាត់ជាភាសារបស់អ្នក។

ប្រាប់ការីទូរសព្ទនូវលេខទូរសព្ទដែលអ្នកចង់ហៅ ហើយការីទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់ម្នាក់ដើម្បីជួយអ្នកក្នុងការសន្ទនា។ គេនឹងមិនគិតថ្លៃសេវានេះពីអ្នកទេ។